ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 05 / 2012
ម៉ោង (Time/Heure) : 08:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

**សាធារណៈ**

# សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

# ថ្ងៃ ពុធ ទី ១៨ ខែ មេសា ឆ្នាំ ២០១២

# សវនាការលើអង្គសេចក្ដី - ថ្ងៃទី ៥១

រៀបចំដោយ: ឌុច ផារី និង Natacha WEXELS-RISER

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោកស្រី Natacha WEXELS-RISER, លោកស្រី សែ កុលវុឌ្ឍី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក Dale LYSAK, លោក វ៉េង ហ៊ត់, លោក Vincent DE WILDE D'ESTMAEL |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Jasper PAUW, លោក Andrew IANUZZI |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta |

| |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT លោក Barnabé NEKUIE, លោកស្រី ជេត វណ្ណលី, លោកស្រី Lyma NGUYEN, លោក ឡោ ជុនធី, លោក Emmanuel JACOMY, លោកស្រី ទី ស្រីនណា |
| សាក្សី៖ សូត្រ ទឿង (TCW-617) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ Phillip GOUT |

| **ពេលវេលាធ្វើការរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃពុធ ទី១៨ ខែមេសា ឆ្នាំ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.១៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖១០.៤០ | បញ្ចប់ម៉ោង៖ ១១.១០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង ៥៥ នាទី | |

| **កិច្ចដំណើរការនីតិវិធី៖** | | | |
|---|---|---|---|
| **ប្រភេទបញ្ហា** | **លើកឡើងដោយ** | **ម៉ោងចាប់ផ្តើម** | **ម៉ោងបញ្ចប់** |
| ការធ្វើសេចក្តីថ្លែងការណ៍ដោយជនជាប់ចោទ នួន ជា | ជនជាប់ចោទ នួន ជា | ៩.១៣ | ៩.២២ |
| ការពិភាក្សាអំពីសិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទ | សហព្រះរាជអាជ្ញា<br>ជនជាប់ចោទ នួន ជា | ៩.២២ | ៩.៣៣ |
| ការតាំងសំណួរដល់សាក្សី សូត្រ ទឿង (TCW-617) | អង្គជំនុំជម្រះ | ៩.៣៦ | ៩.៤៣ |
| សំណើរបស់មេធាវីការពារក្តីធ្វើឡើងតាមវិធាន ២៨ អំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង | មេធាវីការពារកី នួន ជា<br>សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ៩.៤៤<br>១០.២៧ | ៩.៥៦<br>១០.៣៧ |
| ការតាំងសំណួរដល់សាក្សី សូត្រ ទឿង (TCW-617) | សហព្រះរាជអាជ្ញា | ៩.៥៧ | ១០.២៧ |

| | | | |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ១០.៣៥<br>១២.០៥ | ១០.៣៥<br>១២.០៥ |
| សេចក្តីសម្រេចផ្ទាល់មាត់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប | អង្គជំនុំជម្រះ | ១១.១៤ | ១១.១៦ |
| ការធ្វើសវនាការជាអសាធារណៈ អនុលោមតាមវិធាន ២៨ | អង្គជំនុំជម្រះ | ១១.១៥ | ១២.១០ |
| ការតាំងសំណួរដល់សាក្សី សួត្រ ទៀង (TCW-617) | សហព្រះរាជអាជ្ញា | ១៣.៤២ | ១៦.០៦ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធី</u>**

អង្គជំនុំជម្រះប្រកាសបន្តដំណើរការសវនាការ ។

**<u>ការធ្វើសេចក្តីថ្លែងការណ៍ដោយជនជាប់ចោទ នួន ជា</u>**

ជនជាប់ចោទ នួន ជា បដិសេធទៅនឹងសក្ខីកម្មរបស់សាក្សី កាំង ហ្គេចអ៊ាវ ហៅ ឌុច ។ ជនជាប់ចោទ នួន ជា បានបញ្ជាក់ថាគាត់នឹងរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបចំពោះសំណួររបស់ភាគីនោះទេ ។

**<u>ការពិភាក្សាអំពីសិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទ</u>**

ភាគីបង្ហាញពីអំណះអំណាងរបស់ខ្លួនទាក់ទងនឹងបញ្ហាសិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទ ។

**<u>ការតាំងសំណួរដល់សាក្សី សូត្រ ធឿន (TCW-617)</u>**

សហព្រះរាជអាជ្ញាចាប់ផ្តើមការសួរសំណួរដល់សាក្សី ។

**<u>សំណើរបស់មេធាវីការពារក្តីធ្វើឡើងតាមវិធាន ២៨ អំពីសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង</u>**

មេធាវីការពារក្តី នួន ជា ធ្វើសំណើចំនួនពីរ ដោយផ្អែកតាមវិធាន ២៨ (៨) និង ២៨ (៩) ហើយភាគីផ្សេងទៀតធ្វើការឆ្លើយតប ។ អង្គជំនុំជម្រះបដិសេធសំណើសុំទីមួយ (០១) តែទទួលយកសំណើទីពីរ (០២)។

**<u>សេចក្តីសម្រេចផ្ទាល់មាត់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប</u>**

អង្គជំនុំជម្រះប្រកាសសេចក្តីសម្រេចដោយផ្ទាល់មាត់ ទាក់ទងនឹងសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ (សូមមើលសេចក្តីសម្រេចខាងក្រោម)។

**<u>ការធ្វើសវនាការជាអសាធារណៈ អនុលោមតាមវិធាន ២៨</u>**

អង្គជំនុំជម្រះធ្វើសវនាការជាអសាធារណៈ ដើម្បីពិភាក្សាលើសំណើរបស់មេធាវីការពារក្តី ដែលបានធ្វើឡើងតាមវិធាន ២៨ (៨) និង (៩) ។

**ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ តែស្នើសុំចូលរួមសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការតាមរយៈប្រព័ន្ធសោទស្សន៍ ។

**ការតាំងសំណួរដល់សាក្សី សូត្រ ទឿង** (TCW-617)

សហព្រះរាជអាជ្ញាបន្តការសួរសំណួរដល់សាក្សី ។

Record of Rule 87(3) Proceedings

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/423 | D234/23 | 00408429-00408453 00414587-00414611 00434806-00434831 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូត្រ ទឿង SOUTR Toeung Written Record of Interview of SOUTR Toeung សូត្រ ទឿង Procès verbal d'audition de témoin SAUT/SOUTR Toeung សូត្រ ទឿង | P | | | |
| E3/103 | D91/4 | 00204013-00204017 00204018-00204022 00490622-00490626 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូត្រ ទឿង ថ្ងៃទី០៤ ១២ ២០០៧ [Surrogate Sheet] Written Record of Interview of SAUT Toeung [Feuille remplacée] Procès verbal d'audition de SAUT Toeung | P | 00204014 | 00204020 | 00490624 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| E3/146 | D175 /6.2 | 00283389-00283423 00538732-00538757 00611795-00611824 | [លិខិតបញ្ជាក់ការជំនួសឯកសារ] ទស្សនាវដ្ដី យុវជន-យុវនារី បដិវត្តន៍ លេខពិសេស ឆ្នាំ ១៩៧៤ [Surrogate Sheet] Revolutionary Youth Review Number Special year 1974 [Feuille remplacée] Revolutionary Youth Review Number Special year 1974 | P | | | |
| E3/729 | 11.3 | 00063397-00063434 00357900-00357930, 00184230-00184245 00364222-00364251 | យុវជន និង យុវនារី បដិវត្ត លេខ១០ ខែតុលា ឆ្នាំ១៩៧៥ Revolutionary Youth No. 10 Oct., 1975 [Corrigée 1] Revolutionary Youth No. 10 Oct., 1975 | P | | | |
| E3/76 | D262 .45 | 00701871-00701889, 00728971-00728971 00170338-00170455 00701861-00701870, 00743745-00743745 | [លិខិតបញ្ជាក់ការជំនួសឯកសារ] [Partial T.] ឧបសម្ព័ន្ធ ០០០៤៥៖ អៀង សារី រៀបចំពិធីជប់លៀងអាហារថ្ងៃត្រង់ [Surrogate Sheet] Annex 00045: Foreign Broadcast Information Service collection of reports for September 1978 [Feuille remplacée] [Partial T.] Annex 00045: Un déjeuner avec IENG Sary | P | 00701871-00701872 | 00170340 | 00701861 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី (ម៉ោង ១០.៣៧) និង នួន ជា (ម៉ោង ១២.០៧) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរមានភ្ជាប់មកជាមួយនិងកំណត់ហេតុនេះ) ។

- សេចក្តីសម្រេចផ្ទាល់មាត់អំពីសិទ្ធិនៅស្ងៀមរបស់ជនជាប់ចោទ៖

  អង្គជំនុំជម្រះកត់សម្គាល់នូវសំណើសុំពាក់ព័ន្ធនឹងសិទ្ធនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ អៀង សារី និង ខៀវ សំផន (ឯកសារលេខ E ១៦៤ និង E ១៧៤ )។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមថា ក្រោយពីបានធ្វើសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងវគ្គទីមួយនៃការជំនុំជម្រះ ជនជាប់ចោទ នួន ជា បានបញ្ជាក់ថា គាត់អាចរក្សាសិទ្ធនៅស្ងៀមមិនឆ្លើយតប។ អនុលោម តាមមាត្រា ៣៥ ថ្មី (ឆ) នៃច្បាប់ស្តីពីការបង្កើតអវតក ជនជាប់ចោទមិនត្រូវបានបង្ខំឲ្យផ្តល់សក្ខីកម្មប្រឆាំងខ្លួនឯង ឬសារភាពអំពីពិរុទ្ធភាពឡើយ។ ហេតុដូច្នេះ ជនជាប់ចោទមិនអាចត្រូវបានបង្ខំឲ្យឆ្លើយសំណួរដែលត្រូវបានសួរចំពោះគាត់ឡើយ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការវាយតម្លៃអំពីពិរុទ្ធភាព ឬភាពសុចរិតរបស់ជនជាប់ចោទនៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះនឹងពិចារណានូវរាល់ភស្តុតាងដែលបានដាក់នៅចំពោះមុខខ្លួន និងជាកម្មវត្ថុនៃការពិនិត្យ រួមទាំងសក្ខីកម្មរបស់ជនជាប់ចោទ (និងរបៀបដែលជនជាប់ចោទផ្តល់សក្ខីកម្ម)។ ក្នុងន័យនេះ និងនៅពេលដែលជនជាប់ចោទសម្រេចជ្រើសរើសដោយខ្លួនឯង រវាងសិទ្ធិនៅស្ងៀមមិនឆ្លើយតបនិងការផ្តល់សក្ខីកម្មនោះ អង្គជំនុំជម្រះអាចនឹងកត់សម្គាល់អំពីបញ្ហានេះនៅពេលវាយតម្លៃអំពីភាពគួរឲ្យជឿជាក់បានរបស់គាត់។

  យុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធបង្ហាញថា ការសម្រេចជ្រើសរើសដោយខ្លួនឯងក្នុងការនៅស្ងៀមមិនឆ្លើយតបអាចត្រូវបានប្រើក្នុងការទាញចេញជាសេចក្តីសន្និដ្ឋានផ្ទុយ ។ នៅក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះនឹងមិនផ្អែកទាំងស្រុងលើការទាញជាសេចក្តីសន្និដ្ឋានផ្ទុយចេញអំពីការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប នៅក្នុងការវិនិច្ឆ័យអំពីពិរុទ្ធភាពឡើយ។

- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង០៩ ព្រឹក ថ្ងៃព្រហស្បតិ៍ ទី ១៩ ខែ មេសា ឆ្នាំ ២០១២។

**កាលបរិច្ឆេទបន្តសវនាការ៖**

សវនាការនឹងបន្តនៅថ្ងៃព្រហស្បតិ៍ ទី ១៩ ខែ មេសា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ផារី Natacha WEXELS-RISER